**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jan-2013, 15:14
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើតាមវិធាន ៨៧(៤) សុំប្រើប្រាស់ឯកសារមួយក្នុងអំឡុងពេលសួរដេញដោល បដិសាក្សី**

---

<u>ដាក់ដោយ៖</u>

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

Joshua ROSESWEIG

Sofie HOGESTOL

Renee DE GEUS

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**

**Elisabeth SIMONNEAU-FORT**

អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះសូមដាក់សំណើនេះ ("សំណើ") សុំប្រើប្រាស់ឯកសារមួយក្នុងអំឡុងពេលសួរដេញដោលសាក្សី TCW-110 និង TCW-326 ។

១. នៅថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងចេញអនុស្សរណៈមួយដោយបានជូនដំណឹងដល់ភាគីនៃការកំណត់កាលបរិច្ឆេទសវនាការស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញសម្រាប់រយៈពេលបីខែដំបូងនៃឆ្នាំ២០១៣[1]។ អនុស្សរណៈនេះបានចង្អុលបង្ហាញក្នុងចំណោមបញ្ហាដទៃទៀតថា សាក្សី TCW-110 នឹងស្តាប់សក្ខីកម្មក្នុងអំឡុងសប្តាហ៍នៃថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ ។ ការចង្អុលបង្ហាញនោះក្រោយមក ត្រូវបានបញ្ជាក់តាមរយៈសារអេឡិចត្រូនិចមួយពីមន្ត្រីច្បាប់នៅអង្គជំនុំជម្រះ ។ បើតាមក្រុមមេធាវីក្តីដឹង អនុស្សរណៈចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ បង្កើតបានជាការចង្អុលបង្ហាញលើកដំបូងនៃការបរិច្ឆេទមិនផ្លាស់ប្តូរមួយសម្រាប់ការបង្ហាញខ្លួនសាក្សីនេះ បើទោះបីអង្គជំនុំជម្រះបានចង្អុលបង្ហាញកាលពីលើកមុននៃចេតនាទូទៅរបស់ខ្លួន ដើម្បីកោះហៅគាត់ភ្ជាប់ជាមួយផ្នែកជាក់លាក់នៃការជំនុំជម្រះក្នុងករណី ០០២/០១[2] ។

២. នៅក្នុងការរៀបចំសម្រាប់ការសួរដេញដោលសាក្សី TCW-110 ឯកសារសំខាន់មួយដែលមិនមាននៅក្នុងបញ្ជីឯកសាររបស់ភាគីនៅខែ មេសា ឆ្នាំ ២០១១ បានចេញជារូបរាង។ ឯកសារនោះ ដែលមានលេខ A71 ត្រូវគេអះអាងថាជាលិខិត ដែលមួយផ្នែកសរសេរដោយសាក្សី TCW-110 និងមួយផ្នែកទៀតសរសេរដោយសាក្សី TCW-326 អំពី អវតក និង នួន ជា។ សាក្សីទាំងពីរនាក់នេះពេលនេះកំពុងឃុំខ្លួននៅពន្ធនាគារព្រៃសចំពោះការពាក់ព័ន្ធរបស់ពួកគេនៅក្នុងការចាប់ពង្រត់ និងសម្លាប់មនុស្ស ដែលប្រព្រឹត្តនៅដើមទសវត្សឆ្នាំ១៩៩០ ។

---

[1] ឯកសារ E-236/4 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងទៅកាន់ភាគី ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៣ ERN 00876270-00876271, នៅកថាខណ្ឌទី៦ ។

[2] ឯកសារ E-172 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងទៅកាន់ភាគី ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១ ERN 00780654-00780657 ទំព័រ៣ ។ ឯកសារ E-233 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងទៅកាន់ភាគី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ ERN 00848380-00848381 នៅកថាខណ្ឌទី៥ ។

៣. យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះបានយល់ឃើញថា ក្នុងអំឡុងពេលសួរដេញដោលសាក្សី ការប្រើប្រាស់ឯកសារដែលមិនមាននៅក្នុងបញ្ជីឯកសាររបស់ភាគីនាខែ មេសា ឆ្នាំ ២០១១ ត្រូវតែបំពេញវិធាន៨៧(៤)[3]។ អនុលោមតាមវិធាន៨៧(៤) "ក្នុងអំឡុងពេលសវនាការ "អាចទទួលយកបានភស្តុតាងថ្មី បើសិនមិនអាចរកបាននៅមុនសវនាការ ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត និងបំពេញបានលក្ខខណ្ឌទាំងប្រាំសម្រាប់ការទទួលយកជាភស្តុតាង ដែលមានចែងនៅក្នុងវិធាន៨៧(៣)(ក) រហូតដល់(ង)។ យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះបានបង្ហាញពីភាពបត់បែន ទាក់ទងនឹងលក្ខខណ្ឌតម្រូវមិនអាចរកបាននៅមុនសវនាការ ដោយទទួលយកឯកសារជាភស្តុតាងដែលពាក់ព័ន្ធនឹងការសួរដេញដោលសាក្សី នៅពេលមានការជូនដំណឹងគ្រប់គ្រាន់[4]។ អង្គជំនុំជម្រះក៏បានយល់ឃើញថា ជាទូទៅនៅករណីដែលភាគីមួយស្វែងរកឱ្យមានការទទួលយកជាភស្តុតាងនូវឯកសារមួយស្របតាមវិធាន៨៧(៤) ដោយសារភាពពាក់ព័ន្ធរបស់វាទៅនឹងការសួរដេញដោលសាក្សីជាក់លាក់ ភាគីនោះគប្បីស្នើសុំយ៉ាងហោចណាស់រយៈពេលពីរសប្តាហ៍នៅមុនការចូលខ្លួនរបស់សាក្សីដែរ[5]។

៤. វាជាលិខិតមួយដែលអះអាងថាសរសេរដោយសាក្សីទាំងពីរនេះ ហើយពាក់ព័ន្ធដោយផ្ទាល់ទៅនឹងនីតិវិធីនេះ ដូច្នេះដោយសារតែហេតុផលខាងលើតែមួយគត់ (និងឧបមាថាវាដូចជាការអះអាងខាងលើចុះ) ដែលធ្វើឱ្យលិខិតនេះពាក់ព័ន្ធ។ មិនតែប៉ុណ្ណោះ លិខិតនោះបានបង្ហាញពីអរិភាពរបស់សាក្សីនេះប្រឆាំងនឹង នួន ជា ដូច្នេះភាពអាចជឿទុកចិត្តបាននៃសក្ខីកម្មរបស់គាត់គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ វាពិតជាមានសារៈសំខាន់ជាពិសេសដោយសារតែសក្ខីកម្មដោះបន្ទុកដែលផ្តល់ដោយសាក្សី TCW-100 ទាក់ទងនឹង នួន ជា ក្នុងបទសម្ភាសន៍

---

[3] ឯកសារ E-260 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងទៅកាន់ភាគី ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ERN 00879330-00879331 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ")។

[4] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ឯកសារ E-172/24/4 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងទៅភាគី ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ERN 00818308-00818309 នៅកថាខណ្ឌទី៨ ។

[5] ឯកសារ E-218 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងទៅកាន់ភាគី ចុះថ្ងៃ៣ ខែសីហា ឆ្នាំ២០១២ ERN 00831321-00831326, នៅកថាខណ្ឌទី២២។

របស់គាត់ជាមួយនឹងសហចៅក្រមស៊ើបអង្កេត ហើយ (មេធាវីការពារក្តីនៅតែអះអាង) ពីភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងមូលដ្ឋាននៃការដឹងឮរបស់គាត់ចំពោះការអះអាងទាំងនោះ[6]។

៥. យថាភាពនៃលិខិតនេះអាចត្រូវបានបញ្ជាក់យ៉ាងងាយស្រួល (ឬបដិសេធ) ដោយសាក្សីរូបនេះនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម។ លក្ខខណ្ឌដទៃទៀតក្នុងវិធាន៨៧(៣)ក៏ត្រូវបានបំពេញផងដែរៈ លិខិតនោះគឺមិនច្រំដែល និងមិនមានចេតនាពន្យារនីតិវិធី ហើយក៏មិនត្រូវបានជំទាស់ដោយច្បាប់ដែរ។ វានឹងមិនមានផលប៉ះពាល់ចំពោះភាគីណាទាំងអស់ក្នុងការទទួលយកលិខិតនេះជាភស្តុតាងទេ ។

៦. ពាក់ព័ន្ធនឹងសាក្សី TCW-110 មេធាវីការពារក្តីទទួលស្គាល់ថាសំណើនេះមិនបានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវឲ្យជូនដំណឹងជាមុនរយៈពេល២សប្តាហ៍ឡើយ[7]។ ក្នុងន័យនេះមេធាវីការពារក្តីបានកត់សម្គាល់ជាបឋមថា ភាគីត្រូវបានជូនដំណឹងរយៈពេល២០ថ្ងៃនៅមុនកាលបរិច្ឆេទនៃការបង្ហាញខ្លួនរបស់សាក្សី TCW-110 ដោយមានសាក្សីពីរនាក់ផ្សេងទៀតគ្រោងនឹងមកបង្ហាញខ្លួននៅតុលាការក្នុងចន្លោះពេលនោះ។ ការត្រៀមខ្លួនចំពោះសាក្សី TCW-110 បន្ទាប់ពីការជូនដំណឹងរយៈពេល២សប្តាហ៍គឺស្ទើរតែមិនអាចទៅរួច។ មេធាវីការពារសូមកត់សម្គាល់បន្ថែមទៀតថា ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានជ្រាបរួចមកហើយ នៅពេលថ្មីៗមេធាវី

---

[6] ផ្នែកខ្លះនៃលិខិតនេះសរសេរដោយសាក្សី TCW-326 បង្ហាញជាពិសេសអំពីអរិយភាពប្រឆាំង នួន ជា។ មូលហេតុនៃអរិយភាពនោះពាក់ព័ន្ធនឹងព្រឹត្តិការណ៍មួយចំនួនដែលប៉ះពាល់ដល់សាក្សី TCW-326 ផងដែរ ហើយគាត់ក៏អាចយល់ឃើញស្រដៀងគ្នានេះដែរ។ សាក្សី TCW-110 ស្គាល់សាក្សី TCW-326 យ៉ាងច្បាស់ (សូមមើលឯកសារលេខ E3/361, កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ ឈួក រិន, ថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៨ ERN 00766447-0076645 ទំព័រទី៩) ហើយប្រហែលជាត្រូវបានចោទសួរយ៉ាងត្រឹមត្រូវដោយឈរលើមូលដ្ឋាននៃផ្នែកមួយចម្លើយនោះផងដែរ។

[7] ដូចដែលអង្គជំនុំជម្រះបានដឹងហើយថា កំពុងសម្រាកនៅមន្ទីរពេទ្យក្នុងពេលនេះ ហើយមិនអាចចូលរួមក្នុងដំណើរការបាន ។ វាអាចពិតដែលថាសក្ខីកម្ម សាក្សី TCW-110 នឹងអាចត្រូវបានពន្យាពេលដូចនេះការជូនដំណឹងពីរសប្តាហ៍មុននឹងពិតជាបានផ្តល់។ គ្រប់កាលៈទេសៈទាំងអស់ ក្នុងករណីដែលលោក នួន ជា មិនអាចចូលរួម សំណើនេះមិនត្រូវបានបកស្រាយថាជាការយល់ស្របនូវវត្តមានសាក្សី ក្នុងអំឡុងសប្តាហ៍ទី ២៨ ខែ មករា ឆ្នាំ ២០១៣។

អន្តរជាតិបានផ្លាស់ប្តូរសមាសភាពស្ទើរតែទាំងអស់ ហើយបញ្ហានេះអាចជាសម្ពាធធ្ងន់ធ្ងរខាងបុគ្គលិក។ មិនតែប៉ុណ្ណោះឥឡូវនេះ នួន ជា កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយគាត់មិនទាន់អាចពិគ្រោះយោបល់បាន និងចូលរួមក្នុងការការពារក្តីរូបគាត់បានឡើយ។ ដោយសារតែការពិចារណាខាងលើទាំងនេះហើយ សារៈសំខាន់នៃលិខិតនោះក្នុងការស្វែងរកការពិត និងភាពមិនប៉ះពាល់ដល់ភាគីដទៃទៀត មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកលិខិតនេះជាភស្តុតាង។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE